**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងផែនការ

# គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០

# បញ្ជីកែសម្រួល

# ចំណុចដៅ និងសូចនាករ តាមគោលដៅ

ខែកក្កដា ឆ្នាំ២០២២

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា បានប្ដេជ្ញាចិត្ត ក្នុងការធ្វើឱ្យសម្រេចបាន គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ២០១៩-២០៣០ និងរួមចំណែកធ្វើឱ្យសម្រេចបាន គោលដៅអភិវឌ្ឍប្រកបដោយចីរភាព (គ.អ.ច.) តាមរយៈ ការធ្វើមូលដ្ឋាននីយកម្ម គ.អ.ច. សាកល មកក្នុងបរិការណ៍កម្ពុជា និងការអនុវត្ត គ.អ.ច.ក. តាមរយៈការបញ្ជ្រាប គ.អ.ច.ក. ទៅក្នុងប្រព័ន្ធផែនការជាតិ ដែលរួមមាន ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ និងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ។

នៅក្នុងឆ្នាំដំបូង (ឆ្នាំ២០១៩) នៃការអនុវត្ត រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចចិត្តចុះឈ្មោះដើម្បីរៀបចំរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត បង្ហាញពីវឌ្ឍនភាពដល់កិច្ចប្រជុំវេទិកាកម្រិតខ្ពស់ប្រចាំឆ្នាំរបស់អង្គការសហប្រជាជាតិ និងរៀបចំរបាយការណ៍វឌ្ឍនភាព ដើម្បីកំណត់ពីលទ្ធផលនៃការសម្រេចបាន គោលដៅនានារបស់ គ.អ.ច.ក. នេះ។ តាមរយៈលទ្ធផលនៃរបាយការណ៍ទាំងពីរនេះ យើងអាចបញ្ជាក់បានថា ការកំណត់ជ្រើសរើសចំណុចដៅ និងសូចនាករ គ.អ.ច. សម្រាប់បរិការណ៍កម្ពុជានេះ នៅមានភាពខ្វះខាតមួយចំនួន ជាពិសេសមិនទាន់កំណត់បានច្បាស់លាស់ពីប្រភពទិន្នន័យសម្រាប់គាំទ្រ និងសម្រាប់វាយតម្លៃពីលទ្ធផលនៃការសម្រេចបាន។ ជាមួយគ្នានេះ ផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃជំងឺកូវី-១៩ បានធ្វើឱ្យគោលដៅដែលបានកំណត់តាំពីឆ្នាំ ២០១៨ អាចមិនមានសុពលភាពបន្តទៀតដែលទាមទារត្រូវតែធ្វើការកែសម្រួលឡើងវិញ។

ក្រសួងផែនការ បានដឹកនាំ សម្របសម្រួល និងកែសម្រួលបញ្ជីគោលដៅ ចំណុចដៅ និងសូចនាករ ទៅតាមលក្ខខណ្ឌកំណត់ និងទទួលបានជាឯកសារមួយសម្រាប់អនុវត្តដើម្បីឈានទៅសម្រេចបាន បណ្ដាលគោលដៅ ក្នុងអាណត្តិកាលដែលនៅសល់ រហូតដល់ឆ្នាំ២០៣០។

សូមថ្លែងអរគុណដល់ **ឯកឧត្ដម ទូន ថាវរៈ** រដ្ឋលេខាធិការក្រសួងផែនការ និង **ឯកឧត្ដម ថេង បញ្ញាធន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកផែនការ ដែលបានដឹកនាំសម្របសម្រួលក្នុងដំណើរការកែសម្រួលបញ្ជីចំណុចដៅ និងសូចនាករ របស់ គ.អ.ច.ក. នេះ។ សូមអរគុណ ដល់ក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធ ដែលបានសហការផ្ដល់ព័ត៌មាន និងធាតុចូល សម្រាប់កែសម្រួលឯកសារនេះ។ សូមអរគុណផងដែរ ដល់ដៃគូអភិវឌ្ឍនានា ជាពិសេសការិយាល័យអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និង មូលនិធិសហប្រជាជាតិដើម្បីកុមារ ដែលបានសហការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់ការរៀបចំកែសម្រួលបញ្ជីគោលដៅ ចំណុចដៅ និងសូចនាករ នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា នេះ។

ឯកសារនេះ គឺជាសមិទ្ធផលដ៏សំខាន់មួយទៀត របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការអនុវត្តធ្វើឱ្យសម្រេចបាន របៀបវារៈឆ្នាំ២០៣០ ជាពិសេសសម្រាប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា សម្រាប់អនុវត្តឱ្យសម្រេចបាន គ.អ.ច.ក. នៅក្នុងអាណត្តិកាលដែលនៅសល់ និងសម្រាប់ដៃគូអភិវឌ្ឍ និងភាគីអ្នកមានចំណែកពាក់ព័ន្ធ ក្នុងការជួយគាំទ្រសកម្មភាពនានា របស់រាជរដ្ឋាភិបាលកម្ពុជា។

ខ្ញុំមានជំនឿជឿជាក់ថា ការអនុវត្តឯកសារនេះរបស់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ នឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចឱ្យបានចក្ខុវិស័យ ឆ្នាំ២០៣០ និង២០៥០ របស់រាជរដ្ឋាភិបាលកម្ពុជា។

ថ្ងៃ សុក្រ ៣ កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ២០២២

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# តារាងមាតិកា


**អារម្ភកថា** ...... i

**តារាងមាតិកា** ...... iii

**ជំពូកទី១៖ សេចក្ដីផ្ដើម** ...... ១

១.១ ប្រវត្តិដើម ...... ១

១.២ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ ...... ២

១.៣ លទ្ធផលនៃការសម្រេចបាន គ.អ.ច.ក. ឆ្នាំ២០១៩ ...... ៣

១.៤ គោលបំណងនៃការរៀបចំកែសម្រួលបញ្ជី ចំណុចដៅ និងសូចនាករ របស់ គ.អ.ច.ក. ២០១៦-២០៣០ ...... ៤

**ជំពូកទី២៖ ការកែសម្រួលបញ្ជី ចំណុចដៅ និងសូចនាករគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា** ...... ៥

២.១ សេចក្ដីផ្ដើម ...... ៥

២.២ ដំណើរការកែសម្រួល ...... ៥

២.៣ លក្ខខណ្ឌនៃការកែសម្រួល ...... ៦

២.៤ លទ្ធផលនៃការកែសម្រួល ...... ៧

**ជំពូកទី៣៖ ជំហានត្រូវអនុវត្តបន្ត** ...... ១០

៣.១ ការបន្តអនុវត្ត ...... ១០

៣.២ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ...... ១០

**ជំពូកទី៤៖ សេចក្ដីសន្និដ្ឋាន** ...... ១១

**ឧបសម្ព័ន្ធ៖ ពាក្យបំប្រួញ** ...... ១២២


## បញ្ជីតារាង


**តារាងទី១៖ បញ្ជីកែសម្រួលចំណុចដៅ និងសូចនាករគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា តាមគោលដៅ នីមួយៗ** ...... ១៣

គោលដៅទី១ : បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង ...... ១៣

គោលដៅទី២ : បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និង លើកកម្ពស់កសិកម្មប្រកបដោយចីរភាព ...... ១៦

គោលដៅទី៣ : ធានាឱ្យជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពរបស់មនុស្សគ្រប់រូបនិងគ្រប់វ័យ ...... ២០

គោលដៅទី៤ : ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាប័ន្ន និង លើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា .................. ២៦
គោលដៅទី៥ : សម្រេចឱ្យបានសមភាពយេនឌ័រនិងពង្រឹងភាពអង់អាចរបស់ស្ត្រីនិងកុមារីគ្រប់រូប .................................................................................. ៣០
គោលដៅទី៦ : ធានាឱ្យមានទឹកនិងអនាម័យនិងការគ្រប់គ្រងទឹកនិងអនាម័យប្រកបដោយចីរភាពសម្រាប់ប្រជាជនគ្រប់រូប ................................................... ៣៥
គោលដៅទី៧ : ធានាការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់ មានចីរភាព អាចទុកចិត្តបាន និងមានថ្លៃសមរម្យ សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ .............................. ៣៨
គោលដៅទី៨ : ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្ន មានមុខរបរពេញលេញនិងផលិតភាព និងមានការងារសមរម្យសម្រាប់ប្រជាជនគ្រប់រូប .......... ៣៩
គោលដៅទី៩ : កសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងការប្រែប្រួលអាកាសធាតុ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយចីរភាពនិងបរិយាប័ន្ននិងលើកកម្ពស់នវានុវត្តន៍ ៤៦
គោលដៅទី១០ : កាត់បន្ថយវិសមភាពនៅក្នុងប្រទេសនិងក្នុងចំណោមបណ្តាប្រទេសនានា ...... ៥០
គោលដៅទី១១ : ធ្វើឱ្យទីក្រុងនិងកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជន មានលក្ខណៈបរិយាបន្នសុវត្ថិភាព ធន់នឹងការប្រែប្រួលអាកាសធាតុនិងចីរភាព .............................. ៥៤
គោលដៅទី១២ : ធានាឱ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់និងផលិតកម្ម ..................... ៥៥
គោលដៅទី១៣ : ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា ........................................................................ ៥៥
គោលដៅទី១៤ : អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវ មហាសមុទ្រ សមុទ្រ និងធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ......................................... ៥៧
គោលដៅទី១៥ : ការពារ ស្តារ និងជំរុញការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីនៅលើដែនគោក គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ប្រយុទ្ធប្រឆាំងនឹងឱនភាពដី បញ្ឈប់និងបង្វែរទិសនៃការសឹករេចរឹលគុណភាពដី និងបញ្ឈប់កុំឱ្យបាត់បង់ជីជាតិដីនិងជីវៈចម្រុះ ........................................................... ៥៩
គោលដៅទី១៦ : លើកកម្ពស់សង្គមដែលមានសន្តិភាពប្រកបដោយបរិយាបន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប និងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ន នៅគ្រប់កម្រិត ................................................................................ ៦២
គោលដៅទី១៧ : ពង្រឹងមធ្យោបាយអនុវត្តនានា និងបង្កើតភាពរស់រវើកនៃភាពជាដៃគូសកលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ................................................ ៦៣

គោលដៅទី១៨ : បញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និង ជំរុញការសង្គ្រោះជនរងគ្រោះ ........................................................ ៦៨

**តារាងទី២៖ តម្លៃគ្រាដើមនិងចំណុចដៅ កែសម្រួល នៃសូចនាករនីមួយៗ របស់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា** .................. ៧២

គោលដៅទី១ : បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង ........................................ ៧៣

គោលដៅទី២ : បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និង លើកកម្ពស់កសិកម្មប្រកបដោយចីរភាព .................. ៧៥

គោលដៅទី៣ : ធានាឱ្យជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពរបស់មនុស្សគ្រប់រូបនិងគ្រប់វ័យ .................................. ៧៩

គោលដៅទី៤ : ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាប័ន្ន និង លើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា ................ ៨៣

គោលដៅទី៥ : សម្រេចឱ្យបានសមភាពយេនឌ័រនិងពង្រឹងភាពអង់អាចរបស់ស្ត្រីនិងកុមារីគ្រប់រូប .......................................................................................... ៨៧

គោលដៅទី៦ : ធានាឱ្យមានទឹកនិងអនាម័យនិងការគ្រប់គ្រងទឹកនិងអនាម័យប្រកបដោយចីរភាពសម្រាប់ប្រជាជនគ្រប់រូប ........................................................ ៩១

គោលដៅទី៧ : ធានាការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់ មានចីរភាព អាចទុកចិត្តបាន និងមានថ្លៃសមរម្យ សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ ............................ ៩៤

គោលដៅទី៨ : ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្ន មានមុខរបរពេញលេញនិងផលិតភាព និងមានការងារសមរម្យសម្រាប់ប្រជាជនគ្រប់រូប ......... ៩៥

គោលដៅទី៩ : កសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងការប្រែប្រួលអាកាសធាតុ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយចីរភាពនិងបរិយាប័ន្ននិងលើកកម្ពស់នវានុវត្តន៍ ១០១

គោលដៅទី១០ : កាត់បន្ថយវិសមភាពនៅក្នុងប្រទេសនិងក្នុងចំណោមបណ្តាប្រទេសនានា ..... ១០៥

គោលដៅទី១១ : ធ្វើឱ្យទីក្រុងនិងកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជន មានលក្ខណៈបរិយាបន្ន សុវត្ថិភាព ធន់នឹងការប្រែប្រួលអាកាសធាតុនិងចីរភាព ........................... ១០៧

គោលដៅទី១២ : ធានាឱ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់និងផលិតកម្ម ..................... ១០៨

គោលដៅទី១៣ : ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និង ផលប៉ះពាល់របស់វា .......................................................................... ១០៩

គោលដៅទី១៤ : អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវ មហាសមុទ្រ សមុទ្រ និងធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ............................ ១១០

គោលដៅទី១៥ : ការពារ ស្តារ និងជំរុញការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីនៅលើដែនគោក គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ប្រយុទ្ធប្រឆាំងនឹង

ឱនភាពដី បញ្ឈប់និងបង្វែរទិសនៃការសឹករេចរឹលគុណភាពដី និងបញ្ឈប់កុំឱ្យបាត់បង់ជីជាតិដីនិងជីវៈចម្រុះ .......... ១១២

**គោលដៅទី១៦ :** លើកកម្ពស់សង្គមដែលមានសន្តិភាពប្រកបដោយបរិយាបន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប និងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ន នៅគ្រប់កម្រិត .......... ១១៥

**គោលដៅទី១៧ :** ពង្រឹងមធ្យោបាយអនុវត្តនានានិងបង្កើតភាពរស់រវើកនៃភាពជាដៃគូសកលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព .......... ១១៦

**គោលដៅទី១៨ :** បញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងជំរុញការសង្គ្រោះជនរងគ្រោះ .......... ១២០

## បញ្ជីរូបភាព

**រូបភាព ១.១ :** លទ្ធផលនៃការអនុវត្តគោលដៅនៃ គ.អ.ច.ក. ឆ្នាំ២០១៩ .......... ៤

**រូបភាព ២.១ :** សូចនាករ និងចំណុចដៅរបស់គ.អ.ច. សាកល គ.អ.ច.ក. និង គ.អ.ច.ក. កែសម្រួល .......... ៧

**រូបភាព ២.២ :** ចំនួនចំណុចដៅតាមគោលដៅនីមួយៗ របស់ គ.អ.ច. សាកល គ.អ.ច.ក. និង គ.អ.ច.ក. កែសម្រួល .......... ៨

**រូបភាព ២.៣ :** ចំនួនសូចនាករតាមគោលដៅនីមួយៗ របស់ គ.អ.ច. សាកល គ.អ.ច.ក. និង គ.អ.ច.ក. កែសម្រួល .......... ៩

# ជំពូកទី១៖

# សេចក្តីផ្តើម

## ១.១ ប្រវត្តិដើម

គោលដៅអភិវឌ្ឍប្រកបដោយចីរភាពសាកល ត្រូវបានធ្វើមូលដ្ឋាននីយកម្ម មកក្នុងបរិការណ៍កម្ពុជា និងរៀបចំបានជាក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ២០១៦-២០៣០ ដោយទទួលបានការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ២០១៨។ ភ្លាមៗ បន្ទាប់ពីទទួលបានការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា បណ្តាគោលដៅ ចំណុចដៅ និងសូចនាករ ដែលមាននៅក្នុងក្របខ័ណ្ឌ គ.អ.ច.ក. ២០១៦-២០៣០ ត្រូវបានបញ្ជ្រាបចូលក្នុងក្នុងប្រព័ន្ធផែនការជាតិ សម្រាប់អនុវត្ត។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣ គឺជាឧបករណ៍មួយយ៉ាងសំខាន់ សម្រាប់អនុវត្ត ធ្វើឱ្យសម្រេចបាន គ.អ.ច.ក. បន្ថែមលើតួនាទីចម្បងនៃការអនុវត្ត គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។

ជាទូទៅ ដើម្បីវាយតម្លៃពីលទ្ធផលនៃការអនុវត្ត និងសម្រេចបាន គ.អ.ច.ក. រាជរដ្ឋាភិបាលកម្ពុជា បានចុះឈ្មោះជាមួយអង្គការសហប្រជាជាតិ ដើម្បីពិនិត្យមើលជារួមក្នុងកម្រិតជាតិ ពីលទ្ធផលជាក់ស្តែងនៃការសម្រេចបាន គ.អ.ច.ក. ក្នុងឆ្នាំ២០១៩។ របាយការណ៍ដែលមានឈ្មោះថា របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩ នេះ ត្រូវបានរៀបចំជាបន្ទាន់ នៅដើមឆ្នាំ២០១៩ និងត្រូវផ្ញើទៅអង្គការសហប្រជាជាតិ ហើយត្រូវបង្ហាញនៅក្នុងវេទិកានយោបាយកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិ នៅខែកក្កដា ឆ្នាំ២០១៩។

ដោយសារការរៀបចំរបាយការណ៍នេះ មានលក្ខណៈបន្ទាន់ និងប្រើប្រាស់រយៈពេលខ្លីក្នុងឆ្នាំ២០១៩ សូចនាករទាំងអស់ មិនមានទិន្នន័យគាំទ្រ សម្រាប់ឆ្នាំ២០១៩ ទេ និងសូចនាករមួយចំនួនទៀត ក៏មិនមានទិន្នន័យគាំទ្រដែរសម្រាប់ឆ្នាំ២០១៨ ដែលជាហេតុមិនអាចវាយតម្លៃពីលទ្ធផលនៃការសម្រេចបាន របស់សូចនាករទាំងនោះ។ ឆ្លើយតបនឹងបញ្ហានេះ ក្រសួងផែនការបានផ្តួចផ្តើមរៀបចំរបាយការណ៍វឌ្ឍនភាពនៃការសម្រេចបាន គ.អ.ច.ក. ឆ្នាំ២០១៩ ដើម្បីបំពេញបន្ថែមលើរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩។

ផ្អែកលើលទ្ធផលដែលបានរកឃើញ ក្នុងរបាយការណ៍ទាំងពីរនេះមានចំណុចដៅមួយចំនួនពុំមិនទាន់ទិន្នន័យគាំទ្រ និងមានចំណុចដៅមួយចំនួនទៀតសម្រេចបានទាបជាងគោលដៅ

ដែលគ្រោងទុក។ ការពិនិត្យមើលដោយយកចិត្តទុកដាក់ ពីបញ្ហានេះ និងរួមជាមួយមតិស្នើឡើង របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្នុងវេទិកាសេដ្ឋកិច្ចពិភពលោក ឆ្នាំ២០២០ ពីការពិចារណាកែសម្រួលគោលដៅរបស់ គ.អ.ច. ក្រសួងផែនការបានណែនាំដល់ក្រសួង ស្ថាប័ននានា រួមទាំង ភាគីពាក់ព័ន្ធ ឱ្យពិចារណា កែសម្រួលបញ្ជីចំណុចដៅ និងសូចនាករ ផ្អែកលើបញ្ហាប្រឈមដែលបានលើកឡើងខាងលើ។

តាមការពិភាក្សារវាងក្រសួងផែនការ ជាមួយ ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ការកែសម្រួលបញ្ជីចំណុចដៅនិងសូចនាករ ត្រូវបានផ្តោតលើសូចនាករដែលពុំមានទិន្នន័យគាំទ្រ សូចនាករដែលសម្រេចបានទាបគោលដៅគ្រោងទុក និង ក៏អាចពិចារណាឡើងវិញផងដែរចំពោះសូចនាករដែលសម្រេចបានលើសពីគោលដៅគ្រោងទុកច្រើនលើសលុប ដោយបង្កើនតម្លៃចំណុចដៅ។ បន្ថែមលើនេះទៀត ក្រសួងផែនការក៏បានណែនាំដល់ក្រួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ឱ្យពិចារណាលើកឡើងនូវសូចនាករដែលតំណាងឱ្យសកម្មភាព និងកិច្ចខិតខំប្រឹងប្រែងរបស់សាមីស្ថាប័នរបស់ខ្លួន និងរួមចំណែកធ្វើសម្រេចបានគោលដៅណាមួយ នៃ គ.អ.ច.ក. ដើម្បីបញ្ចូលក្នុងបញ្ជីចំណុចដៅ និងសូចនាករ។

## ១.២ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០

ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ បានទទួលការអនុម័ត កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨។ ផ្អែកលើគោលដៅអភិវឌ្ឍប្រកបដោយចីរភាពសាកល (គ.អ.ច.) និងផ្អែកលើការគិតគូពីស្ថានភាពសង្គម សេដ្ឋកិច្ចរបស់កម្ពុជា ដែលអាចទទួលយកបាននូវបណ្តាគោលដៅ ចំណុចដៅ និងសូចនាករ មកអនុវត្តក្នុងបរិការណ៍កម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចកំណត់យកគោលដៅចំនួន ១៨ ដែលត្រូវបានបន្ថែមគោលដៅជាតិ ១ លើគោលដៅទាំងអស់ដែលទទួលយកពីគោលដៅសាកល ចំណុចដៅចំនួន ៨៨ ធៀបនឹងចំណុចដៅសាកលមានចំនួន ១៦៩ និង សូចនាករចំនួន ១៤៨ ដែលក្នុងនោះរួមបញ្ចូលទាំងសូចនាករជាតិចំនួន៩៦ ធៀបនឹងសូចនាករសាកលមានចំនួន ២៣២។

ក្របខ័ណ្ឌ គ.អ.ច.ក. ២០១៦-២០៣០ មិនមែនជាផែនការសកម្មភាពទេ។ ដើម្បីអនុវត្ត និងធ្វើឱ្យសម្រេចបាន គ.អ.ច.ក. នេះ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងផែនការ បានបញ្ជ្រាបបណ្តាគោលដៅ ចំណុចដៅ និងសូចនាកររបស់ គ.អ.ច.ក. ទៅក្នុងប្រព័ន្ធផែនការជាតិ ជាពិសេស ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ និងផែនការនៅថ្នាក់ក្រោមជាតិ។

បន្ទាប់ពីអនុវត្ត ក្នុងរយៈពេលខ្លី ក្នុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានចុះឈ្មោះជាមួយអង្គការសហប្រជាជាតិ ដើម្បីវាយតម្លៃពីលទ្ធផលនៃការសម្រេចបាន គ.អ.ច.ក. តាមរយៈការរៀបចំរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩ និង ត្រូវបានបំពេញបន្ថែមតាមរយៈ ការរៀបចំរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក.។

របាយការណ៍ទាំងពីរនេះ ត្រូវបានបោះពុម្ព និងផ្សព្វផ្សាយ ទាំងនៅក្នុង និងក្រៅប្រទេស និងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ១.៣ លទ្ធផលនៃការសម្រេចបាន គ.អ.ច.ក. ឆ្នាំ២០១៩

ការវាយតម្លៃពីវឌ្ឍនភាពនៃការសម្រេចបាន សូចនាករ និងចំណុចដៅរបស់ គ.អ.ច.ក. ត្រូវបានបែងចែកនិងបង្ហាញ ជា ៣កម្រិត ដូចខាងក្រោម៖

**ក. លើសចំណុចដៅ៖** គឺជាការបង្ហាញឱ្យឃើញពីលទ្ធផលល្អប្រសើរ ដែលជាការអនុវត្តបានលើសតម្លៃចំណុចដៅដែលបានកំណត់១០% នៅក្នុងឆ្នាំអនុវត្តនីមួយៗ។

**ខ. ស្ថិតលើគន្លងឈានទៅសម្រេចបាន៖** គឺជាលទ្ធផលល្អ ដែលជាការកំណត់បង្ហាញតម្លៃនៃលទ្ធផលអនុវត្តនៅចន្លោះរវាងក្រោមតម្លៃចំណុចដៅដែលបានកំណត់ត្រឹម១០% និងលើសតម្លៃចំណុចដៅដែលបានកំណត់ត្រឹម១០% នៅក្នុងឆ្នាំអនុវត្តនីមួយៗ។

**គ. ទាបជាងចំណុចដៅ៖** គឺជាលទ្ធផល ដែលជាការកំណត់បង្ហាញតម្លៃនៃលទ្ធផលអនុវត្ត ទាបជាង តម្លៃចំណុចដៅដែលបានកំណត់១០% នៅក្នុងឆ្នាំអនុវត្តនីមួយៗ។

ក្រៅពីកម្រិតទាំង៣ នៃការវាយតម្លៃនេះ **គ្មានទិន្នន័យ** នឹងត្រូវផ្តល់ជាការកំណត់ចំណាំចំពោះសូចនាករឬចំណុចដៅណា ដែលពុំមានទិន្នន័យគាំទ្រសម្រាប់ការវាយតម្លៃពីលទ្ធផលនៃការអនុវត្ត នៅក្នុងអាណត្តិកាលនៃការរៀបចំរបាយការណ៍វឌ្ឍនភាពនេះ។ ការពុំមានទិន្នន័យគាំទ្រ ត្រូវបានចែកចេញជាពីរផ្នែកគឺ **ទី១** សំដៅលើការពុំមិនមានប្រភពទិន្នន័យគាំទ្រ សម្រាប់ការវាយតម្លៃពីលទ្ធផលនៃការសម្រេចបាន សូចនាករឬចំណុចដៅ របស់ គ.អ.ច.ក. និង **ទី២** មានប្រភពទិន្នន័យគាំទ្រ ប៉ុន្តែពុំមានវដ្តសម្រាប់ផលិតនៅក្នុងអាណត្តិកាលនៃការរៀបចំរបាយការណ៍ (ក្នុងករណីរបាយការណ៍នេះ គឺឆ្នាំ២០១៩) ជាពិសេស ទិន្នន័យដែលពឹងផ្អែកលើអង្កេត ឬជំរឿននានាដែលមានរយៈពេលវែង (៥ឆ្នាំ ឬ១០ឆ្នាំម្តង) ដូច អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា អង្កេតពាក់កណ្តាលជំរឿន និងជំរឿនជាដើម។

## រូបភាព ១.១៖ លទ្ធផលនៃការអនុវត្តគោលដៅនៃ គ.អ.ច.ក. ឆ្នាំ២០១៩




## ១.៤ គោលចំណងនៃការរៀបចំកែសម្រួល បញ្ជីចំណុចដៅ និងសូចនាករ របស់ គ.អ.ច.ក. ២០១៦-២០៣០

ក្នុងចំណោមចំណុចដៅចំនួន៨៨ មាន១៨ (ស្មើនឹង២០,៤៥%) គ្មានទិន្នន័យគាំទ្រ ដែលក្នុងនោះ មានតែប្រមាណជាង ១ភាគ៣ ពុំមានប្រភពទិន្នន័យ ចំណែកឯសូចនាករជិត២ភាគ៣ទៀត មានប្រភពទិន្នន័យគាំទ្រ តែពុំមានវដ្តទិន្នន័យផលិតសម្រាប់ការវាយតម្លៃលទ្ធផលអនុវត្ត គ.អ.ច.ក. ក្នុងឆ្នាំ២០១៩ នេះទេ ដូចនេះ អាចចាត់ទុកថា ពុំមានទិន្នន័យក្នុងឆ្នាំ២០១៩ តែនឹងអាចមានទិន្នន័យគាំទ្រនៅឆ្នាំខាងមុខ ដែលមានវដ្តទិន្នន័យផលិត។ ផ្អែកលើការកំណត់ខាងលើ លទ្ធផលដែលបង្ហាញក្នុងរបាយការណ៍វឌ្ឍភាពឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក. បញ្ជាក់ថា៖

- ៣១,៨២% នៃចំណុចដៅ៖ សម្រេចលើសគោលដៅកំណត់ដៅ
- ៣១,៨២% នៃចំណុចដៅ៖ ស្ថិតលើគន្លងទៅសម្រេចបានតាមការកំណត់
- ១៥,៩១% នៃចំណុចដៅ៖ សម្រេចបានទាបជាងគោលដៅកំណត់
- ២០,៤៥% នៃចំណុចដៅ៖ គ្មានទិន្នន័យ (រួមទាំង គ្មានវដ្តទិន្នន័យ និង គ្មានប្រភពទិន្នន័យ)។

ដូចនេះ ការកែសម្រួលនឹងផ្តោតការយកចិត្តទុកដាក់លើ សូចនាករដែលពុំមានប្រភពទិន្នន័យគាំទ្រ ប្រមាណ ២០,៤៥% និង ចំណុចដៅដែលសម្រេចបានទាបជាងគោលដៅដែលបានគ្រោងទុក ជាមួយគ្នានឹងផលប៉ះពាល់ដែលបានកើតមាន ពីការរីករាលដាលនៃជំងឺកូវីដ-១៩ មកលើសង្គមសេដ្ឋកិច្ចកម្ពុជា។

# ជំពូកទី២៖

# ការកែសម្រួលបញ្ជី ចំណុចដៅ និងសូចនាករ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា

## ២.១ សេចក្តីផ្តើម

ផ្អែកលើលទ្ធផលនៃការវាយតម្លៃលទ្ធផលនៃការអនុវត្ត គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ដែលបានបង្ហាញតាមរយៈ *របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩* និង*របាយការណ៍វឌ្ឍនភាពភាពឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក.* ផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងដោយផ្អែកតាមប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ថ្លែងក្នុងវេទិកាសេដ្ឋកិច្ចពិភពលោក កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ដែលបានស្នើឱ្យអង្គការសហប្រជាជាតិពិនិត្យមើលឡើងវិញពីគោលដៅ ចំណុចដៅ របស់គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ដូចនេះ កម្ពុជាក៏ត្រូវកែសម្រួលបណ្តាគោលដៅនានា រួមទាំងគោលដៅជាតិ ដែលមាននៅក្នុង គ.អ.ច.ក. និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

## ២.២ ដំណើរការនៃការកែសម្រួល

ការងារកែសម្រួលបញ្ជីគោលដៅ និងចំណុចដៅ និងសូចនាករ របស់ គ.អ.ច.ក. នេះ បានចាប់ផ្តើមតាំងពីខែកក្កដា ឆ្នាំ២០២០ ដោយក្រសួងផែនការបានសំណូមពរឱ្យក្រសួង ស្ថាប័ននានាពិនិត្យពិចារណាកែសម្រួលសូចនាករនានា ដែលពុំមានទិន្នន័យគាំទ្រ ពិនិត្យមើលសូចនាករដែលមិនសម្រេចបានតាមគោលដៅកំណត់ និងពិចារណាបន្ថែមនូវសូចនាករមួយចំនួន ដែលអាចរំលេចនូវកិច្ចខំប្រឹងប្រែងរបស់ស្ថាប័ន ក្នុងការចូលរួមធ្វើឱ្យសម្រេចបាន គ.អ.ច.ក.។ ប៉ុន្តែមកដល់ខែកុម្ភៈ ឆ្នាំ២០២១ ដោយសារចាប់ផ្តើមមានការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងផែនការក៏បានណែនាំបន្ថែមដល់ក្រសួងស្ថាប័ននានា ឱ្យពិចារណាពីផលប៉ះពាល់នៃការរីករាលដាលនៃមេរោគរាតត្បាតសាកលនេះ មកលើដំណើរការឆ្ពោះទៅសម្រេចបាន គ.អ.ច.ក. នេះ។ នៅក្នុងរយៈពេលនៃការរីករាលដាលជំងឺកូវីដ-១៩នេះ ទោះបីយើងពុំមានពេលវេលាធ្វើការងារ និងជួបគ្នាដើម្បីពិភាក្សាដោយផ្ទាល់ដើម្បីបញ្ចប់ការងារនេះក្តី យើងក៏បានដំណើរការការងារអនឡាញដើម្បីបញ្ចប់ការងារនេះ។

សេចក្តីព្រាងកែសម្រួលបញ្ជី ចំណុចដៅ និងសូចនាករ គ.អ.ច.ក. ត្រូវបានពិភាក្សាចំនួនបីលើក គឺកម្រិតបច្ចេកទេសពីរលើក ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ និងថ្ងៃទី១៩ខែកុម្ភៈ ឆ្នាំ២០២១ និងបន្ទាប់ពីទទួលបានអនុសាសន៍នានា ពីក្រសួងស្ថាប័ន លើសេចក្តីព្រាងនៃបញ្ជីចំណុចដៅ និងសូចនាករនេះ ក្រសួងផែនការបានរៀបចំកិច្ចប្រជុំម្តងទៀតកម្រិតនយោបាយនាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ ដើម្បីពិនិត្យនិងផ្តល់ការឯកភាពលើសេចក្តីព្រាងជាចុងក្រោយ។ ជាថ្មីម្តងទៀត ដើម្បីប្រាកដថា រាល់អនុសាសន៍ និងការកែសម្រួលរបស់ក្រសួង ស្ថាប័ន ត្រូវបានដាក់បញ្ចូលក្នុងឯកសារនេះ ក្រសួងផែនការ បានផ្ញើសេចក្តីព្រាងចុងក្រោយទៅក្រសួង ស្ថាប័ន ដើម្បីពិនិត្យជាចុងក្រោយ។ សេចក្តីព្រាងនេះ ត្រូវបានអនុម័ត កាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២។

## ២.៣ លក្ខខណ្ឌនៃការកែសម្រួល

ដូចបានបញ្ជាក់នៅក្នុងផ្នែកខាងលើ ការកែសម្រួលបញ្ជីចំណុចដៅ និងសូចនាករ ត្រូវបាននែនាំដោយក្រសួងផែនការ ដែលមាន៧ចំណុច សំខាន់ៗ គឺ

- ការកែសម្រួលត្រូវផ្អែកលើលទ្ធផលនៃការសម្រេចបាន គ.អ.ច.ក. ដែលបានបង្ហាញក្នុងរបាយការណ៍វឌ្ឍនភាព ឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក. ដោយផ្តោតជាសំខាន់លើសូចនាករដែលពុំមានប្រភពទិន្នន័យគាំទ្រ (ចំនួន១៣ ស្មើ ៨,៧៨%) និងសូចនាករដែលអនុវត្តបានទាបជាងគោលដៅដែលបានកំណត់ (ចំនួន ២២ ស្មើ ១៤,៨៦%) និងផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩។
- ពិចារណាដកចេញ (ឬស្វែងរកប្រភពទិន្នន័យគាំទ្រ) ចំពោះសូចនាករដែលពុំមានប្រភពទិន្នន័យគាំទ្រ។
- កែសម្រួលសូចនាករ (រួមទាំងបំពេញនូវលក្ខខណ្ឌរបស់សូចនាករ) ដើម្បីអាចអនុវត្តនិងអាចមានប្រភពទិន្នន័យគាំទ្រ។
- កែសម្រួលតម្លៃចំណុចដៅ ដោយបង្កើនឬបន្ថយ ផ្អែកលើស្ថានភាពជាក់ស្តែង (រួមទាំងផលប៉ះពាល់នៃការរីករាលដាលរបស់មេរោគកូវីដ-១៩) ដែលអាចសម្រេចបាន។
- កែសម្រួលវដ្តទិន្នន័យ ផ្អែកតាមវដ្តនៃប្រភពទិន្នន័យ (ដូចជាវដ្តនៃអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ជាដើម)។
- ផ្តោតសំខាន់ចំពោះវិស័យដែលមានសូចនាករពុំមានប្រភពទិន្នន័យគាំទ្រ ឬមានសូចនាករដែលអនុវត្តបានទាបជាងគោលដៅដែលបានកំណត់។

- ពិចារណាដាក់បញ្ចូលសូចនាករថ្មីបន្ថែម ដើម្បីបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នខ្លួន ក្នុងការចូលរួមចំណែកធ្វើឱ្យសម្រេចបាន គ.អ.ច.ក.។

## ២.៤ លទ្ធផលនៃការកែសម្រួល

ផ្អែកលើលក្ខខណ្ឌដែលបានកំណត់ខាងលើ ក្រសួងផែនការបានទទួលនូវការកែសម្រួលតាមវិស័យ និងស្ថាប័ន ដោយភាគច្រើន មានការកែសម្រួលតម្លៃចំណុចដៅ របស់សូចនាករមួយចំនួន កែសម្រួល ឬដកចេញពីបញ្ជី នូវសូចនាករណាដែលកំណត់ថា ពុំអាចរកប្រភពទិន្នន័យគាំទ្រ និងបន្ថែមនូវសូចនាករមួយចំនួន តាមលក្ខខណ្ឌនៃការមានប្រភពទិន្នន័យគាំទ្រ ដែលកំណត់ថា បានរួមចំណែកធ្វើឱ្យសម្រេចបាន គោលដៅនៃ គ.អ.ច.ក.។

ជារួមបន្ទាប់ពីការកែសម្រួល គ.អ.ច.ក. មានគោលដៅចំនួន ១៨ ចំណុចដៅចំនួន ៩៥ (កើនឡើង ៧) និងសូចនាករចំនួន ១៨៥ (កើនឡើង ៣៧)។

**រូបភាព ២.១៖ សូចនាករ និងចំណុចដៅរបស់ គ.អ.ច. សាកល គ.អ.ច.ក. និង គ.អ.ច.ក. កែសម្រួល**



បើពិនិត្យមើលចំនួននៃចំណុចដៅ តាមគោលដៅនីមួយៗ របស់ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា យើងឃើញថា មានគោលដៅចំនួន១១ ដែលមានចំនួនចំណុចដៅមានការប្រែប្រួល គឺ៖

- គោលដៅចំនួន៩ គឺ គោលដៅទី២, ទី៥, ទី៦, ទី៨, ទី៩, ទី១០, ទី១១, ទី១៦, និងទី១៧ មានចំនួនចំណុចដៅកើនឡើង។
- គោលដៅចំនួន២ គឺ គោលដៅទី១២, និងទី១៣ មានចំនួនចំណុចដៅថយចុះ។ (សូមមើលរូបភាពទី២)។

**រូបភាព ២.២៖ ចំនួនចំណុចដៅតាមគោលដៅនីមួយៗ របស់ គ.អ.ច. សាកល គ.អ.ច.ក. និង គ.អ.ច.ក. កែសម្រួល**




ដូចគ្នាដែរ ចំនួនសូចនាករ ក៏មានការប្រែប្រួលតាមគោលដៅមួយចំនួនដែរ និងមួយចំនួនទៀត មិនមានការប្រែប្រួលទេ។ ក្នុងរូបភាពទី៣ បង្ហាញថា មានគោលដៅចំនួន១១ មានចំនួនសូចនាករកើនឡើង គោលដៅចំនួន៤ មានចំនួនសូចនាករថយចុះ និងគោលដៅផ្សេងទៀត ពុំមានការប្រែប្រួលទេ។

- គោលដៅចំនួន១១ គឺ គោលដៅទី១, ទី២, ទី៣, ទី៥, ទី៦, ទី៨, ទី៩, ទី១០, ទី១៤, ទី១៦, និងទី១៧ ដែលចំនួនសូចនាករកើនឡើង។
- គោលដៅចំនួន៤ គឺ គោលដៅទី៤, ទី១១,ទី១២, ទី១៣ មានចំនួនសូចនាករថយចុះ។

## រូបភាព ២.៣៖ ចំនួនសូចនាករ តាមគោលដៅនីមួយៗ របស់ គ.អ.ច. សាកល គ.អ.ច.ក. និង គ.អ.ច.ក. កែសម្រួល



# ជំពូកទី៣៖

# ជំហានត្រូវអនុវត្តបន្ត

## ៣.១ ការបន្តអនុវត្ត

ក្រោយពីទទួលបានការអនុម័ត បញ្ជីកែសម្រួលចំណុចដៅ និងសូចនាករ ត្រូវបានបញ្ជ្រាបទៅក្នុងវិធានការគោលនយោបាយ ក្នុងរបាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ ហើយនឹងត្រូវបានបញ្ជ្រាបទៅក្នុង ប្រព័ន្ធផែនការជាតិ ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០២៤-២០២៨ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ និងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ ដើម្បីបន្តអនុវត្តដើម្បីធ្វើឱ្យសម្រេចបាន គ.អ.ច.ក.។ ចំពោះ ផ.យ.អ.ជ. ២០២៤-២០២៨ នឹងចាប់ផ្តើមរៀបចំ នៅដើមឆ្នាំ២០២៣ ខាងមុខនេះ។ សូចនាកររបស់ គ.អ.ច.ក. ដែលមាននៅក្នុងឯកសារនេះនឹងត្រូវបានបញ្ចូលក្នុងបញ្ជីសូចនាករស្នូល សម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃ ។

## ៣.២ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

លទ្ធផលនៃអនុវត្តឱ្យសម្រេចបាន គ.អ.ច.ក. នេះ នឹងត្រូវបានតាមដានត្រួតពិនិត្យ និងវាយតម្លៃ។ តាមការគ្រោងទុក រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងផែនការ នឹងរៀបចំរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត នៅឆ្នាំ២០២២ ដោយចាប់ផ្តើមពីត្រីមាសទី៣ ឆ្នាំ២០២២ និងផ្តល់របាយការណ៍នេះ និងបង្ហាញនៅវេទិកាអង្គការសហប្រជាជាតិ នៅឆ្នាំ២០២៣។ ការវាយតម្លៃពីលទ្ធផលសម្រេចបាននេះ ក៏នឹងត្រូវបានដាក់បញ្ចូលផងដែរក្នុងការវាយតម្លៃពីការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ នៅពេលរៀបចំផែនការជាតិនេះ សម្រាប់អាណត្តិកាលថ្មី។ ជាទូទៅ ការវាយតម្លៃពីការសម្រេចបាន គ.អ.ច.ក. នឹងត្រូវធ្វើជារៀងរាល់ ២ឆ្នាំម្តង ឬ ប្រចាំឆ្នាំផ្អែកលើពេលវេលា និងថវិកាគាំទ្រ។

# ជំពូកទី៤៖

# សេចក្តីសន្និដ្ឋាន

គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា គឺជាឯកសារគន្លឹះតាងមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបង្ហាញឱ្យឃើញពីការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរួមចំណែកធ្វើឱ្យសម្រេចបាន គោលដៅអភិវឌ្ឍប្រកបដោយចីរភាព (គ.អ.ច.) សាកល។ ទោះបីជាមិនបានរៀបចំផែនការសកម្មភាពដាច់ដោយឡែកសម្រាប់អនុវត្ត គ.អ.ច.ក. នេះក្តី ប៉ុន្តែ ការបញ្ជ្រាបបណ្តាគោលដៅ ចំណុចដៅ និងសូចនាករ ទៅក្នុង ប្រព័ន្ធផែនការជាតិ សម្រាប់អនុវត្តនេះ គឺជាការផ្តល់តម្លៃ នៃគោលដៅនានារបស់ គ.អ.ច.ក. ឱ្យស្មើនឹងគោលដៅជាតិ ដែលបានកំណត់នៅក្នុង ផែនការ។ម្យ៉ាងវិញទៀត ដោយសារគោលដៅ មួយចំនួន នៃ គ.អ.ច.ក. មានលក្ខណៈប្រហាក់ប្រហែលគ្នា ឬដូចគ្នានឹងគោលដៅជាតិ ដូចនេះ មិនមានការចាំបាច់សម្រាប់រៀបចំផែនការសម្មភាពដាច់ដោយឡែកសម្រាប់អនុវត្ត គ.អ.ច.ក. ទេ។

រាជរដ្ឋាភិបាលកម្ពុជាជឿជាក់ថា ការអនុវត្ត គ.អ.ច.ក. តាមរយៈប្រព័ន្ធផែនការជាតិ នឹងរួមចំណែកធ្វើឱ្យសម្រេចបាន គ.អ.ច. សាកល ក៏ដូចជាធ្វើឱ្យសម្រេចបានគោលដៅអាទិភាពតាមវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា តាមវិស័យ ឈានទៅ ស្តារសេដ្ឋកិច្ចជាតិឡើងវិញបន្ទាប់ពីការរីករាលដាលនៃកូវីដ-១៩ ដោយជំរុញកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រនិងលើកកម្ពស់កម្រិតជីវភាពរស់របស់ប្រជាជនកម្ពុជា ព្រមទាំងឈានទៅសម្រេចបានទស្សនវិស័យរបស់កម្ពុជា ឆ្នាំ ២០៥០។

# តារាងទី១

# បញ្ជីកែសម្រួលចំណុចដៅ និងសូចនាករ
# គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា
# តាមគោលដៅនីមួយៗ

# តារាងទី១ : បញ្ជីកែសម្រួល ចំណុចដៅ និងសូចនាករគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា តាមគោលដៅនីមួយៗ

| ចំណុចដៅ | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | វដ្តនៃទិន្នន័យ | និយមន័យ | វិធីសាស្ត្រគណនាតម្លៃសូចនាករ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | ភាគយក | ភាគបែង | |
| **គោលដៅទី១៖ បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង** | | | | | | | | |
| ១.២ កាត់បន្ថយយ៉ាងតិចពាក់កណ្តាលនូវសមាមាត្រនៃបុរស ស្ត្រី និងកុមារ គ្រប់អាយុ ដែលរស់នៅក្នុងភាពក្រីក្រ គ្រប់សមាសភាព ដោយផ្អែកលើនិយមន័យរបស់កម្ពុជា នៅត្រឹមឆ្នាំ២០៣០។ | ១.២.១. សមាមាត្រនៃប្រជាជនកម្ពុជារស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ បែងចែកតាម ភេទ អាយុ និងតំបន់ភូមិសាស្ត្រ។ | ក្រសួងផែនការ និង ក្រុមការងារជាតិសម្រាប់វាស់វែងភាពក្រីក្រ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា | រៀងរាល់ពីរឆ្នាំ | ចំនួនប្រជាជនកម្ពុជាដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ ក្នុងចំណោមចំនួនប្រជាជនកម្ពុជាសរុប បែងចែកតាម ភេទ អាយុ និងតំបន់ភូមិសាស្ត្រ។ | ចំនួនប្រជាជនកម្ពុជាដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ បែងចែកតាម ភេទ អាយុ និងតំបន់ភូមិសាស្ត្រ នៅក្នុងឆ្នាំ។ | ចំនួនប្រជាជនកម្ពុជាសរុប បែងចែកតាម ភេទ អាយុ និងតំបន់ភូមិសាស្ត្រ នៅក្នុងឆ្នាំ។ | MOP |
| | ១.២.១.១ សមាមាត្រនៃប្រជាជនកម្ពុជារស់នៅក្រោម ខ្សែបន្ទាត់ភាពក្រីក្រជាតិ។ | ក្រសួងផែនការ និង ក្រុមការងារជាតិសម្រាប់វាស់វែងភាពក្រីក្រ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា | រៀងរាល់ពីរឆ្នាំ | ចំនួនប្រជាជនកម្ពុជាដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ ក្នុងចំណោមចំនួនប្រជាជនកម្ពុជាសរុប។ | ចំនួនប្រជាជនកម្ពុជាដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ នៅក្នុងឆ្នាំ។ | ចំនួនប្រជាជនកម្ពុជាសរុប នៅក្នុងឆ្នាំ។ | MOP |
| | ១.២.១.២ សមាមាត្រនៃប្រជាជនកម្ពុជានៅរាជធានីភ្នំពេញ ដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ។ | ក្រសួងផែនការ និង ក្រុមការងារជាតិសម្រាប់វាស់វែងភាពក្រីក្រ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា | រៀងរាល់ពីរឆ្នាំ | ចំនួនប្រជាជនកម្ពុជានៅរាជធានីភ្នំពេញ រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ ក្នុងចំណោមចំនួនប្រជាជនកម្ពុជាទាំងអស់ដែលរស់នៅរាជធានីភ្នំពេញ។ | ចំនួនប្រជាជនកម្ពុជានៅរាជធានីភ្នំពេញដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ នៅក្នុងឆ្នាំរាយការណ៍។ | ចំនួនសរុបនៃប្រជាជនកម្ពុជារស់នៅរាជធានីភ្នំពេញ នៅក្នុងឆ្នាំរាយការណ៍។ | MOP |
| | ១.២.១.៣ សមាមាត្រនៃប្រជាជនកម្ពុជានៅតំបន់ទីប្រជុំជន ដែលរស់នៅ | ក្រសួងផែនការ និង ក្រុមការងារជាតិសម្រាប់វាស់វែងភាពក្រីក្រ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា | រៀងរាល់ពីរឆ្នាំ | ចំនួនប្រជាជនកម្ពុជានៅតំបន់ទីប្រជុំជន រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ ក្នុងចំណោម | ចំនួនប្រជាជនកម្ពុជានៅតំបន់ទីប្រជុំជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ | ចំនួនសរុបនៃប្រជាជនកម្ពុជារស់នៅតំបន់ទីប្រជុំជន នៅក្នុងឆ្នាំរាយការណ៍។ | MOP |

| ចំណុចដៅ | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | វដ្តនៃទិន្នន័យ | និយមន័យ | វិធីសាស្ត្រគណនាតម្លៃសូចនាករ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | ភាគយក | ភាគបែង | |
| | ក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ។ | | | | ចំនួនប្រជាជនកម្ពុជាសរុបដែលរស់នៅតំបន់ទីប្រជុំជន។ | ជាតិ នៅក្នុងឆ្នាំរាយការណ៍។ | | |
| | ១.២.១.៤ សមាមាត្រនៃប្រជាជនកម្ពុជា នៅតំបន់ជនបទ ដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ។ | ក្រសួងផែនការ និង ក្រុមការងារជាតិសម្រាប់វាស់វែងភាពក្រីក្រ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា | រៀងរាល់ពីរឆ្នាំ | ចំនួនប្រជាជនកម្ពុជានៅតំបន់ជនបទរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ ក្នុងចំណោមចំនួនប្រជាជនកម្ពុជាសរុបរស់នៅតំបន់ជនបទ។ | ចំនួនប្រជាជនកម្ពុជានៅតំបន់ជនបទដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ នៅក្នុងឆ្នាំរាយការណ៍។ | ចំនួនសរុបនៃប្រជាជនកម្ពុជារស់នៅតំបន់ជនបទ នៅក្នុងឆ្នាំរាយការណ៍។ | **MOP** |
| | ១.២.១.៥ សមាមាត្រនៃកុមារកម្ពុជា ( 0-១៧ឆ្នាំ ) រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ។ | ក្រសួងផែនការ និង ក្រុមការងារជាតិសម្រាប់វាស់វែងភាពក្រីក្រ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា | រៀងរាល់ពីរឆ្នាំ | ចំនួនកុមារកម្ពុជា (អាយុ 0-១៧ឆ្នាំ ) រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ ក្នុងចំណោមចំនួនកុមារកម្ពុជា (អាយុ 0-១៧ឆ្នាំ ) សរុប។ | ចំនួនកុមារកម្ពុជា ( អាយុ 0-១៧ឆ្នាំ ) ដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ នៅក្នុងឆ្នាំរាយការណ៍។ | ចំនួនកុមារកម្ពុជា ( អាយុ 0-១៧ឆ្នាំ ) សរុបនៅក្នុងឆ្នាំរាយការណ៍។ | **MOP** |
| | ១.២.២ សមាមាត្រនៃប្រជាជនកម្ពុជា ដែលរស់នៅក្នុងភាពងាយរងគ្រោះ ផ្អែកលើពហុសមាសភាគតាមនិយមន័យរបស់ជាតិ។ | ក្រសួងផែនការ និង ក្រុមការងារជាតិសម្រាប់វាស់វែងភាពក្រីក្រ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា / អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា | រៀងរាល់ពីរឆ្នាំ | សមាមាត្រនៃចំនួនប្រជាជនកម្ពុជាដែលមិនបានទទួលការបំពេញតម្រូវការជាមូលដ្ឋានដែលមានទំនាក់ទំនងយ៉ាងសំខាន់ចំពោះសុខុមាលភាព រួមមានសុខភាពនិងអាហារូបត្ថម្ភ ទឹកស្អាតនិងអនាម័យ ការអប់រំ ការការពារ និងលំនៅឋាន ធៀបនឹងចំនួនប្រជាជនសរុប។ | ចំនួនប្រជាជនកម្ពុជា ដែលមិនបានទទួលការបំពេញតម្រូវការជាមូលដ្ឋានដែលមានទំនាក់ទំនងយ៉ាងសំខាន់ចំពោះសុខុមាលភាព រួមមានសុខភាពនិងអាហារូបត្ថម្ភ ទឹកស្អាតនិងអនាម័យ ការអប់រំ ការការពារ និងលំនៅឋាន នៅក្នុងឆ្នាំរាយការណ៍។ | ចំនួនប្រជាជនសរុប នៅក្នុងឆ្នាំរាយការណ៍។ | **MOP** កំពុងកំណត់វិធីសាស្ត្រ |

| ចំណុចដៅ | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | វដ្តនៃទិន្នន័យ | និយមន័យ | វិធីសាស្ត្រគណនាតម្លៃសូចនាករ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | ភាគយក | ភាគបែង | |
| | ១.២.២.១ សមាមាត្រកុមារ (០-១៧ឆ្នាំ) ដែលរស់នៅក្នុងភាពក្រីក្រ/ភាពងាយរងគ្រោះ ផ្អែកលើពហុសមាសភាគ តាមនិយមន័យរបស់ជាតិ។ | ក្រសួងផែនការ និងក្រុមការងារជាតិសម្រាប់វាស់វែងភាពក្រីក្រ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា / អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា | រៀងរាល់ ៥ឆ្នាំ | សមាមាត្រនៃកុមារកម្ពុជា (អាយុ ០-១៧ឆ្នាំ) ដែលមិនបានទទួលការបំពេញតម្រូវការជាមូលដ្ឋានដែលមានទំនាក់ទំនងយ៉ាងសំខាន់ចំពោះសុខុមាលភាពកុមាររួមមានសុខភាពនិងអាហារូបត្ថម្ភ ទឹកស្អាតនិងអនាម័យ ការអប់រំ ការការពារ និងលំនៅឋាន។ | ចំនួនកុមារកម្ពុជា (អាយុ ០-១៧ឆ្នាំ) ដែលមិនបានទទួលការបំពេញតម្រូវការជាមូលដ្ឋានយ៉ាងហោចណាស់ចំនួន៣ ក្នុងចំណោមទាំង៥សមាសភាគ នៅក្នុងឆ្នាំរាយការណ៍។ | ចំនួនកុមារកម្ពុជា (អាយុ ០-១៧ឆ្នាំ) សរុប នៅក្នុងឆ្នាំរាយការណ៍។ | **MOP** |
| ១.៣ អនុវត្តប្រព័ន្ធជាតិគាំពារសង្គមនិងវិធានការផ្សេងៗ ឱ្យបានទូទាំងប្រទេស និងសម្រេចឱ្យបានភាគច្រើននូវភាពគ្របដណ្តប់នៃប្រព័ន្ធនេះ ដល់ប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះ នៅត្រឹមឆ្នាំ២០៣០។ | ១.៣.១ សមាមាត្រនៃជនក្រីក្រ និងជនងាយរងគ្រោះដែលទទួលបានសេវាជំនួយសង្គម។ | ក្រុមប្រឹក្សាជាតិគាំពារសង្គម | ប្រព័ន្ធព័ត៌មានរដ្ឋបាលក្រុមប្រឹក្សាជាតិគាំពារសង្គម<br>ក្រសួងផែនការ | ប្រចាំឆ្នាំ | ចំនួនប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្ររបស់ជាតិ និងប្រជាជនដែលពុំអាចទប់ទល់បាន នឹងវិបត្តិឬដែលមានភាពប្រឈម ខ្ពស់ទៅនឹងវិបត្តិ (ប្រជាជនដែលរស់នៅក្រោមឬក្បែរបន្ទាត់ភាព ក្រីក្រ ហើយមានភាពងាយរងគ្រោះខ្ពស់ជាងគេ) ដែលទទួលបានសេវាជំនួយសង្គម ក្នុងចំណោមជនក្រីក្រនិងជនងាយរងគ្រោះសរុប | ចំនួនជនក្រីក្រនិងជនងាយរងគ្រោះ ដែលទទួលបានសេវាជំនួយសង្គម នៅក្នុងឆ្នាំរាយការណ៍។ | ចំនួនជនក្រីក្រនិងជនងាយរងគ្រោះសរុប នៅក្នុងឆ្នាំរាយការណ៍។ | **NSPC** |
| ១.៤ ត្រឹមឆ្នាំ២០៣០ ធានាថា បុរសស្ត្រីគ្រប់រូប ជាពិសេសប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះ | ១.៤.១ ភាគរយនៃសមាជិកសហគមន៍នេសាទនិងព្រៃឈើ ដែលទទួលបានសិទ្ធិស្របច្បាប់ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រព័ន្ធព័ត៌មានរដ្ឋបាលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រចាំឆ្នាំ | ចំនួនសមាជិកសហគមន៍នេសាទនិងព្រៃឈើដែលទទួលបានសិទ្ធិស្របច្បាប់ក្នុងការចូល | ចំនួនសមាជិកសហគមន៍ នេសាទនិងព្រៃឈើដែលទទួលបានសិទ្ធិស្របច្បាប់ក្នុងការចូលរួមគ្រប់គ្រងធនធាន | ចំនួនសមាជិកសហគមន៍នេសាទនិងព្រៃឈើសរុបគិតត្រឹមឆ្នាំរាយការណ៍។ | **MAFF** |

| ចំណុចដៅ | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | វដ្តនៃទិន្នន័យ | និយមន័យ | វិធីសាស្ត្រគណនាតម្លៃសូចនាករ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | ភាគយក | ភាគបែង | |
| មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ធនធានសេដ្ឋកិច្ច និងក្នុងការទទួលបានសេវាមូលដ្ឋាន ភាពជាម្ចាស់ និងការគ្រប់គ្រងដី និងកម្មសិទ្ធិផ្សេងទៀត ធនធានធម្មជាតិ បច្ចេកវិទ្យាថ្មីៗសមស្របនិងសេវាហិរញ្ញវត្ថុ រួមទាំងមីក្រូហិរញ្ញវត្ថុ។ | ក្នុងការចូលរួមគ្រប់គ្រងធនធានជលផលនិងព្រៃឈើ តាមរយៈការចុះបញ្ជីនិងអភិវឌ្ឍសហគមន៍ប្រកបដោយប្រសិទ្ធភាព។ | | | | រួមគ្រប់គ្រងធនធានជលផលនិងព្រៃឈើតាមរយៈការចុះបញ្ជីនិងអភិវឌ្ឍសហគមន៍ប្រ កបដោយប្រសិទ្ធភាពក្នុងចំណោមសហគមន៍នេ សាទនិងព្រៃឈើសរុប។ | ជលផលនិងព្រៃឈើតាមរយៈការ ចុះបញ្ជីនិងអភិវឌ្ឍសហគមន៍ប្រកបដោយប្រសិទ្ធភាព គិតត្រឹមឆ្នាំរាយការណ៍ | | |
| | ១.៤.២ ភាគរយនៃចំនួនប្រជាជនពេញវ័យដែលទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ (ឥណទានប្រាក់បញ្ញើ និងទូទាត់)។ | ធនាគារជាតិនៃកម្ពុជា | ស្ទង់មតិ/ទិន្នន័យរដ្ឋបាល | ប្រចាំឆ្នាំ | ចំនួនប្រជាជនពេញវ័យ (១៨ឆ្នាំឡើង) សរុបទូទាំងប្រទេស ដែលប្រើប្រាស់សេវាហិរញ្ញវត្ថុ រួមមាន ឥណទាន ប្រាក់បញ្ញើ និងទូទាត់ ធៀបនឹងចំនួនប្រជាជនពេញវ័យសរុបទូទាំងប្រទេស | ចំនួនប្រជាជនពេញវ័យប្រើប្រាស់សេវាហិរញ្ញវត្ថុ នៅក្នុងឆ្នាំរាយការណ៍។ | ចំនួនប្រជាជនពេញវ័យសរុបទូទាំងប្រទេស នៅក្នុងឆ្នាំរាយការណ៍។ | **NBC** |
| **គោលដៅទី២៖ បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព។** | | | | | | | | |
| ២.១ ត្រឹមឆ្នាំ២០៣០ បញ្ចប់ភាពអត់ឃ្លាន និងធានាថាប្រជាជនគ្រប់រូប ពិសេស ប្រជាជនក្រីក្រ ជនងាយរងគ្រោះ និងកុមារ ទទួលបានម្ហូបអាហារគ្រប់គ្រាន់ពេញមួយឆ្នាំៗ។ | ២.១.១. ប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភ (ប្រជាជន)។ | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្មនិងជនបទ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា | រៀងរាល់ពីរឆ្នាំ | ភាគរយនៃប្រជាជន ប្រើប្រាស់អាហារថាមពលស្ថិតក្រោមកម្រិតអប្បរមា គឺត្រូវបានកំណត់ជាភាគរយនៃប្រជាជន ក្នុងចំណោមប្រជាជនសរុបដែលរងគ្រោះដោយសារភាពអត់ឃ្លាន ឬខ្វះស្បៀងម្ហូបអាហារ។ | ចំនួនប្រជាជនប៉ាន់ស្មាននៅក្នុងប្រទេស ដែលមានកម្រិតទទួលទានអាហារមិនគ្រប់គ្រាន់សម្រាប់បំពេញតំរូវការថាមពល និងដើម្បីធ្វើឱ្យជីវិតមានភាពសកម្ម និងមានសុខភាពល្អធម្មតា នៅក្នុងឆ្នាំរាយការណ៍។ | ចំនួនសរុបនៃប្រជាជនក្នុងប្រទេស នៅក្នុងឆ្នាំរាយការណ៍។ | CARD |
| | ២.១.២ ប្រេវ៉ាឡង់អសន្តិសុខស្បៀង(កម្រិតធ្ងន់និងមធ្យម)របស់ប្រជាជនដោយផ្អែកលើបទ | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា | រៀងរាល់ពីរឆ្នាំ | អសន្តិសុខស្បៀងគឺត្រូវបានកំណត់ថា ជាភាពលំបាករបស់ប្រជាជនក្នុងការទទួលបាន | អាស្រ័យលើការអង្កេតចំនួនប៉ាន់ស្មាននៃគ្រួសារនៅក្នុងប្រទេសដែលមានបុគ្គលម្នាក់ឬច្រើននាក់ បាន | ចំនួនសរុបនៃគ្រួសារ នៅក្នុងប្រទេស ក្នុងឆ្នាំរាយការណ៍។ | CARD |

| ចំណុចដៅ | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | វដ្តនៃទិន្នន័យ | និយមន័យ | វិធីសាស្ត្រគណនាតម្លៃសូចនាករ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | ភាគយក | ភាគបែង | |
| | ពិសោធន៍ធ្វើបទដ្ឋានសន្តិសុខស្បៀង (FIES)។ | | | | ស្បៀងអាហារដែលមានគុណភាពនិងបរិមាណគ្រប់គ្រាន់ដោយសារពុំមានថវិកា ឬធនធានដទៃទៀត។ បញ្ហាទាំងនោះក៏ទាក់ទងនឹងចិត្តសាស្ត្របុគ្គលផងដែរក្នុងការតស៊ូដើម្បីទទួលបានស្បៀងអាហារ។ | ជួបប្រទះនឹងបញ្ហាអសន្តិសុខស្បៀងក្នុងកម្រិតមធ្យម ឬធ្ងន់ធ្ងរ នៅក្នុងឆ្នាំវាយការណ៍។ | | |
| ២.២ ត្រឹមឆ្នាំ២០៣០ បញ្ចប់គ្រប់ទម្រង់នៃកង្វះអាហារូបត្ថម្ភ រួមទាំងការសម្រេចបាននៅឆ្នាំ ២០២៥ នូវ ចំណុចដៅដែលបានឯកភាពក្នុងកម្រិតអន្តរជាតិ ស្តីពីភាពក្រិននិងភាពស្គមស្គាំងរបស់កុមារអាយុក្រោមអាយុ៥ឆ្នាំ និងដោះស្រាយនូវតម្រូវការអាហារូបត្ថម្ភរបស់កុមារីវ័យជំទង់ ស្ត្រីមានផ្ទៃពោះ ស្ត្រីកំពុងបំបៅដោះកូន និង ស្ត្រីវ័យចាស់។ | ២.២.១ ប្រេវ៉ាឡង់នៃភាពក្រិន(កម្ពស់ធៀបនឹងអាយុមានកម្រិតទាបជាងបទដ្ឋានរីកលូតលាស់មធ្យម របស់កុមារ របស់អង្គការសុខភាពពិភពលោក) ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ។ | ពណ៌នាទិន្នន័យត្រួតពិនិត្យ និងធ្វើរបាយការណ៍ដោយក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដៃគូដែលចូលរួម។ | ប្រមូលទិន្នន័យដោយៈ ក្រសួងផែនការ/ក្រសួងសុខាភិបាល។ | រៀងរាល់៥ឆ្នាំ | ភាពក្រិនគឺកម្ពស់ទាបធៀបនឹងអាយុ ហើយសូចនាករនេះវាស់វែងកុមារដែលមានអាយុ ក្រោមនិង៥ឆ្នាំដែលកម្ពស់ធៀបនឹងអាយុមានកម្រិតបទដ្ឋានរីកលូតលាស់ ២ឬច្រើនស្ថិតនៅក្រោមកម្ពស់ជាមធ្យមធៀបនឹងអាយុរបស់កុមារ។ | ចំនួនកុមារដែលមានកម្ពស់ធៀបនឹងអាយុ Z គឺមានកម្រិតបទដ្ឋាន ២ឬច្រើនស្ថិតនៅក្រោមកម្រិតរីកលូតលាស់មធ្យម នៃកម្ពស់ធៀបនឹងអាយុរបស់កុមារ។ | ចំនួនកុមាររស់ដែលមានអាយុចន្លោះពី 0 ដល់ ៥៩ខែ មុនការអង្កេត។ | **CARD** |
| | ២.២.២ ប្រេវ៉ាឡង់នៃភាពស្គមស្គាំងឬលើសទម្ងន់ (ទម្ងន់ធៀបនឹងកម្ពស់មានកម្រិតទាបជាងឬខ្ពស់ជាងបទដ្ឋានរីកលូតលាស់មធ្យមរបស់អង្គការសុខភាពពិភពលោក (>+2 ឬ <-2)) របស់កុមារ ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ ទៅតាមប្រភេទ | ពណ៌នាទិន្នន័យ ត្រួតពិនិត្យ និងធ្វើរបាយការណ៍ដោយ ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ។ **ដៃគូដែលចូលរួម** | ប្រមូលទិន្នន័យដោយ ក្រសួងផែនការ/ក្រសួងសុខាភិបាល។ | រៀងរាល់៥ឆ្នាំ | សន្ទស្សន៍ទំងន់ធៀបនឹងកម្ពស់ត្រូវបានវាស់វែងពីម៉ាសរាងកាយដែលទាក់ទងនឹងប្រវែងរាងកាយ និងពណ៌នាពីស្ថានភាព អាហារូបត្ថម្ភ។ កុមារដែលមានពិន្ទុ Z គឺស្ថិតនៅក្រោមចំនួនសង (-2 SD) នៃបទដ្ឋានមធ្យមរបស់ប្រជាជនដែលមានភាព | ចំនួននៃកុមារដែលមានទំងន់ធៀបនឹងកម្ពស់ពិន្ទុ Z គឺជាបទដ្ឋានរីកលូតលាស់២ ឬច្រើន ដែលស្ថិតនៅក្រោមមធ្យមនៃទំងន់ធៀបនឹងកម្ពស់របស់ប្រជាជន។ | ចំនួននៃកុមាររស់នៅ មានអាយុចន្លោះពី 0 ដល់ ៥៩ខែ មុនការអង្កេត និងកុមារដែលមានតាមសំណាកនៃការអង្កេត។ | **CARD** |

| ចំណុចដៅ | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | វដ្តនៃទិន្នន័យ | និយមន័យ | វិធីសាស្ត្រគណនាតម្លៃសូចនាករ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | ភាគយក | ភាគបែង | |
| | នីមួយៗ នៃភាពស្គមស្គាំង ឬលើសទម្ងន់។ | USAID, WFP, UNICEF, WHO, SUN-CSA-CAM | | | ស្គមស្គាំង ធៀបនឹងកម្ពស់ និងខ្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។ | | | |
| ២.៣ ត្រឹមឆ្នាំ២០៣០ ទទួលបានកំណើនទ្វេដងនៃផលិតភាពក្នុងវិស័យកសិកម្ម និងចំណូលរបស់ផលិតករធុនតូចជាពិសេសស្ត្រីក្នុងគ្រួសារទុរគត គ្រួសារកសិករ អ្នកគង្វាល និងអ្នកនេសាទតាមរយៈការធានានិងការទទួលបានស្មើភាពគ្នានូវដីធ្លី ធនធានផលិតកម្មផ្សេងទៀត និងធាតុចូល ចំណេះដឹង សេវាហិរញ្ញវត្ថុ ទីផ្សារ និងកាលានុវត្តភាពសម្រាប់តម្លៃបន្ថែម និងការងារក្នុងផ្នែកមិនមែន កសិកម្ម។ | ២.៣.១ ទំហំផលិតកម្មកសិកម្មក្នុងកសិករម្នាក់ដែលប្រកបរបរកសិកម្ម(ស្រែចម្ការ ការចិញ្ចឹមសត្វ និងជលផល)។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ | ប្រព័ន្ធព័ត៌មានរដ្ឋបាលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ | ប្រចាំឆ្នាំ | តម្លៃផលិតផលកសិកម្មក្នុងកសិករម្នាក់ ដែលប្រកបរបរស្រែចម្ការ ការចិញ្ចឹមសត្វ និងជលផលក្នុងមួយឆ្នាំ។ | តម្លៃនៃផលិតផលកសិកម្មសរុប (ពីស្រែចម្ការ ការចិញ្ចឹមសត្វ និងជលផល) នៅក្នុងឆ្នាំរាយការណ៍។ | ចំនួនពលកម្មសរុបក្នុងវិស័យកសិកម្ម (ស្រែចម្ការ ការចិញ្ចឹមសត្វ និងជលផល) ក្នុងឆ្នាំរាយការណ៍។ | **MAFF** |
| ២.៤ ត្រឹមឆ្នាំ២០៣០ ធានានូវប្រព័ន្ធផលិតកម្មស្បៀងអាហារដែលមានចីរភាព អនុវត្តសកម្មភាពកសិកម្មដោយមានការឆ្លើយតបនឹងការប្រែប្រួលអាសធាតុ ដែលជួយឱ្យមានការកើនឡើងនូវផលិតកម្មនិងផលិតផល ជួយថែរក្សាប្រព័ន្ធអេកូឡូស៊ី ជួយពង្រឹងសមត្ថភាពសម្រាប់ធន់នឹងការប្រែប្រួលអាកាសធាតុអាក្រក់ | ២.៤.១ ផលិតភាពដីកសិកម្មដែលបាននិងកំពុងប្រើប្រាស់ដើម្បីធ្វើកសិកម្មប្រកបដោយចីរភាព។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ | ទិន្នន័យរដ្ឋបាលក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ។ | ប្រចាំឆ្នាំ | តម្លៃផលិតផលកសិកម្មជាមធ្យម ក្នុងមួយហិកតា ក្នុងមួយឆ្នាំ។ | តម្លៃផលិតផលកសិកម្មសរុប នៅក្នុងឆ្នាំ។ | ផ្ទៃដីកសិកម្មសរុបដែលបាននិងកំពុងប្រើប្រាស់ធ្វើកសិកម្មប្រកបដោយចីរភាព នៅក្នុងឆ្នាំ។ | **MAFF** |

| ចំណុចដៅ | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | វដ្តនៃទិន្នន័យ | និយមន័យ | វិធីសាស្ត្រគណនាតម្លៃសូចនាករ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | ភាគយក | ភាគបែង | |
| ភាពរាំងស្ងួត ទឹកជំនន់ និងគ្រោះមហន្តរាយផ្សេងទៀត និង ធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់នូវគុណភាពដី។ | | | | | | | | |
| ២.៥ ត្រឹមឆ្នាំ២០២០ រក្សាការធ្វើពិពិធកម្មហ្សែននៃគ្រាប់ពូជការធ្វើកសិកម្មនិងចំការ ការផ្សាំពូជសត្វ និងប្រភេទសត្វព្រៃដែលពាក់ព័ន្ធ តាមរយៈការគ្រប់គ្រងសមស្រប ការធ្វើពិពិធកម្មនិងរក្សាគ្រាប់ពូជ នៅកម្រិតជាតិ តំបន់ និងអន្តរជាតិ និង លើកកម្ពស់ការទទួលបានចំណែកប្រកបដោយយុត្តិធម៌និងសមធម៌ នៃផលប្រយោជន៍ពីការប្រើប្រាស់ធនធានហ្សែន និងចំណេះដឹងប្រពៃណីដែលពាក់ព័ន្ធ ដូចការឯកភាពជាអន្តរជាតិ។ | ២.៥.១ ចំនួនធនធានពន្ធុរុក្ខជាតិសម្រាប់ស្បៀងអាហារនិងកសិកម្ម ដែលបានធានាក្នុងគោលនយោបាយ យុទ្ធសាស្ត្រនិងទីកន្លែងអភិរក្ស រយៈពេលមធ្យម ឬរយៈពេលវែង។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន។ | ក្រសួងបរិស្ថាន/អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ។ | រៀងរាល់៣ឆ្នាំ | ចំនួនធនធានពន្ធុរុក្ខជាតិ សម្រាប់គាំទ្រវិស័យស្បៀងនិងកសិកម្ម។ | ចំនួនធនធានពន្ធុរុក្ខជាតិសម្រាប់ស្បៀងអាហារនិងកសិកម្មបានអភិវឌ្ឍនិងរក្សាទុក នៅត្រឹមឆ្នាំរាយការណ៍។ | | MAFF |
| | ២.៥.២ ចំនួនសហគមន៍នៅតំបន់ការពារធម្មជាតិបានលើកកម្ពស់កម្រិតជីវភាព តាមរយៈទទួលផលប្រយោជន៍ពីអនុផលព្រៃឈើ (NTFPs) ផលនេសាទ ការអភិវឌ្ឍកសិកម្មចម្រុះ និងការអភិវឌ្ឍអេកូទេសចរណ៍ធម្មជាតិ នៅក្នុងតំបន់ការពារធម្មជាតិ។ | ក្រសួងបរិស្ថាន | អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន/ក្រសួងបរិស្ថាន និងអង្គការ ដៃគូ។ | ប្រចាំឆ្នាំ | ចំនួនសហគមន៍តំបន់ការពារធម្មជាតិបានលើកកម្ពស់កម្រិតជីវភាព តាមរយៈការដកហូត និងការកែច្នៃអនុផលព្រៃឈើ ផលនេសាទ កសិកម្មចម្រុះ និងការផ្តល់សេវាអេកូទេសចរណ៍ធម្មជាតិ និងការអភិរក្សជីវៈចម្រុះ និងនិរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ី។ | ចំនួនសហគមន៍តំបន់ការពារធម្មជាតិដំណើរការ។ | | MOE |
| ២.a បង្កើនការវិនិយោគ តាមរយៈការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទ ការស្រាវ | ២.a.១ លំហូរនៃហិរញ្ញប្បទានសរុប (ហិរញ្ញប្បទានសហប្រតិបត្តិការ និងលំហូរផ្សេងទៀត) ដល់វិស័យ | គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ | ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជា | ប្រចាំឆ្នាំ | ទំហំនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់វិស័យកសិកម្មតាមឆ្នាំនីមួយៗ ធៀបនឹង ផលិតផល | ទំហំនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់វិស័យកសិកម្មនៅក្នុងឆ្នាំ។ | ផលិតផលក្នុងស្រុកសរុប នៅក្នុងឆ្នាំ។ | CRDB/CDC |

| ចំណុចដៅ | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | វដ្តនៃទិន្នន័យ | និយមន័យ | វិធីសាស្ត្រគណនាតម្លៃសូចនាករ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | ភាគយក | ភាគបែង | |
| ជ្រាវនិងសេវាផ្សព្វផ្សាយកសិកម្ម និង ការអភិវឌ្ឍបច្ចេកវិជ្ជានិងធនាគារហ្សែនរុក្ខជាតិនិងសត្វ ដើម្បីលើកកម្ពស់សមត្ថភាពផលិតក្នុងប្រទេសកម្ពុជា។ | កសិកម្ម ធៀបនឹងផលិតផលក្នុងស្រុកសរុប។ | | | | ក្នុងស្រុកសរុប ក្នុងឆ្នាំនីមួយៗ។ | | | |
| **គោលដៅទី៣៖ ធានាជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពរបស់មនុស្សគ្រប់រូប និងគ្រប់វ័យ។** | | | | | | | | |
| ៣.១ កម្រិតនៃការអភិវឌ្ឍនៅប្រទេសកម្ពុជា សុខភាពនិងសុខមាលភាពរបស់ប្រជាពលរដ្ឋ និងបង្ការហានិភ័យហិរញ្ញវត្ថុ។ | ៣.១.១ អាយុសង្ឃឹមរស់ពីកំណើត។ | ក្រសួងសុខាភិបាល | ក្រសួងផែនការ (ជំរឿន អង្កេតចន្លោះជំរឿន និង អង្កេតប្រជាសាស្ត្រនិងសុខភាព)។ | រៀងរាល់៥ឆ្នាំ | រយៈពេលមធ្យមនៃជីវិតរស់នៅរបស់ប្រជាជនម្នាក់ក្នុងប្រទេសមួយគិតជាឆ្នាំ ដែលត្រូវបានគណនាពីពេលចាប់កំណើត រហូតដល់ស្លាប់។ | រយៈពេលមធ្យមនៃជីវិតរស់នៅរបស់ប្រជាជនម្នាក់គិតជាឆ្នាំ ដែលត្រូវបានគណនាពីពេលចាប់កំណើត រហូតដល់ស្លាប់ នៅក្នុងឆ្នាំរាយការណ៍។ | | MOH |
| | ៣.១.២ អត្រាលទ្ធភាពបង្កើតកូនសរុប (ចំនួនកូនកើតក្នុងស្ត្រីម្នាក់)។ | ក្រសួងសុខាភិបាល | ក្រសួងផែនការ (ជំរឿន អង្កេតចន្លោះជំរឿន និង អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា)។ | រៀងរាល់៥ឆ្នាំ | គឺជាចំនួនកូនជាមធ្យម ដែល ត្រូវបានផ្តល់កំណើតរស់ ដោយស្ត្រីក្នុងវ័យបន្តពូជ ម្នាក់។ | ចំនួនកូនដែលកើតរស់សរុប ត្រឹមឆ្នាំរាយការណ៍។ | ចំនួនស្ត្រីដែលស្ថិតក្នុងវ័យបន្តពូជ (១៥ ដល់ ៤៩ឆ្នាំ) សរុប គិតត្រឹមឆ្នាំរាយការណ៍។ | MOH |
| ៣.២ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយអត្រាមរណភាពមាតានៅកម្រិតសាកល ឱ្យនៅកម្រិតទាបជាង ៧០ករណីក្នុងចំណោម ១០០ ០០០ កំណើតរស់។ | ៣.២.១ អត្រាមរណភាពមាតា (ក្នុង ១០០ ០០០ កំណើតរស់)។ | ក្រសួងសុខាភិបាល | ក្រសួងផែនការ (ជំរឿន អង្កេតចន្លោះជំរឿន និង អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា)។ | រៀងរាល់៥ឆ្នាំ | គឺជាចំនួននៃការស្លាប់របស់ស្ត្រីក្នុងវ័យន្តពូជប្រចាំឆ្នាំដែលបណ្តាលមកពីមូលហេតុណាមួយ ឬទាក់ទងនឹងភាពធ្ងន់ធ្ងរនៃផ្ទៃពោះឬការគ្រប់គ្រងខ្លួនផ្ទាល់ (លើកលែងដោយមូលហេតុចៃដន្យនិងការជួបឧបទ្ទវ | ចំនួននៃការស្លាប់របស់ស្ត្រីអាយុពី១៥-៤៩ឆ្នាំ នៅឆ្នាំរាយកាណ៍ ដែលមកពីមូលហេតុណាមួយ ឬទាក់ទងនឹងភាពធ្ងន់ធ្ងរនៃផ្ទៃពោះឬការគ្រប់គ្រងខ្លួនផ្ទាល់ (លើកលែងដោយមូលហេតុចៃដន្យនិងការជួបឧបទ្ទវហេតុ) នៅក្នុងអំឡុងពេល | ចំនួនស្ត្រីអាយុពី១៥-៤៩ឆ្នាំ ដែលសម្រាលកូន (កើតរស់) នៅក្នុងឆ្នាំរាយការណ៍។ | MOH |

| ចំណុចដៅ | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | វដ្តនៃទិន្នន័យ | និយមន័យ | វិធីសាស្ត្រគណនាតម្លៃសូចនាករ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | ភាគយក | ភាគបែង | |
| | | | | | ហេតុ) ក្នុងអំឡុងពេលមានផ្ទៃពោះនិងសម្រាលកូន ឬក្នុងរយៈពេល ៤២ថ្ងៃក្រោយបញ្ចប់នៃការមានផ្ទៃពោះ ដោយមិនគិតពី រយៈពេលនិងទីតាំងនៃការមានផ្ទៃពោះ ក្នុងចំណោម ១០០ ០០០កំណើតរស់ ។ | មានផ្ទៃពោះនិងសម្រាលកូន ឬក្នុងរយៈពេល ៤២ថ្ងៃក្រោយបញ្ចប់នៃការមានផ្ទៃពោះ ដោយមិនគិតពីរយៈពេលនិងទីតាំងនៃការមានផ្ទៃពោះ។ | | |
| | ៣.២.២ ភាគរយនៃការសម្រាលដោយបុគ្គលិកសុខាភិបាលមានជំនាញ។ | ក្រសួងសុខាភិបាល | ក្រសួងសុខាភិបាល/ប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យាសុខាភិបាល តាមគេហទំព័រ ក្រសួងផែនការ (ជំរឿន អង្កេតចន្លោះជំរឿន និង អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា) | ប្រចាំឆ្នាំ | ផ្តោតលើសមាមាត្រចំនួននៃការសម្រាលកូនដោយ បុគ្គលិកសុខាភិបាលមានជំនាញ រួមមាន វេជ្ជបណ្ឌិត គ្រូពេទ្យជំនួយ ឆ្មប និងគិលានុប្បដ្ឋាកយិការដោយមិនរាប់បញ្ចូលឆ្មបបុរាណ (នៅមូលដ្ឋានសុខាភិបាលនិងនៅផ្ទះ) ក្នុងចំណោមចំនួននៃការសម្រាលកូនសរុប។ | ចំនួនសម្រាលកូនដោយបុគ្គលិកសុខាភិបាលមានជំនាញ នៅក្នុងឆ្នាំរាយការណ៍។ | ចំនួនស្ត្រីមានផ្ទៃពោះរំពឹងទុក | **MOH** |
| ៣.៣ ត្រឹមឆ្នាំ២០៣០ បញ្ចប់ការស្លាប់ដែលអាចការពារបាន នៃទារកទើបកើតនិងកុមារអាយុក្រោម ៥ឆ្នាំ ដោយគ្រប់ប្រទេសទាំងអស់មានគោលដៅកាត់បន្ថយមរណភាពទារកទើបកើត ដល់ត្រឹម ១២ ក្នុង១ ០០០កំណើតរស់ និងមរណភាពកុមារក្រោមអាយុ៥ឆ្នាំ យ៉ាង | ៣.៣.១ អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ (ក្នុង ១០០០កំណើតរស់)។ | ក្រសួងសុខាភិបាល | ក្រសួងផែនការ (ជំរឿន អង្កេតចន្លោះជំរឿន អង្កេតប្រជាសាស្ត្រនិងសុខភាពម្ពុជា) | រៀងរាល់៥ឆ្នាំ | ផ្តោតលើវិធានប្រូបាប៊ីលីតេនៃកុមារដែលកើតក្នុងឆ្នាំជាក់លាក់ឬរយៈពេលនៃការស្លាប់មុនពេលឈានដល់អាយុ៥ឆ្នាំក្នុង ១ ០០០កំណើតរស់។ | ចំនួនកុមារស្លាប់ក្នុងអាយុក្រោម៥ឆ្នាំ នៅក្នុងឆ្នាំរាយការណ៍។ | ចំនួនទារកកើតរស់សរុប នៅឆ្នាំរាយការណ៍។ | **MOH** |
| | ៣.៣.២ អត្រាមរណភាពទារកទើបកើត (ក្នុង ១ ០០០ ទារកកើតរស់)។ | ក្រសួងសុខាភិបាល | ក្រសួងផែនការ (អង្កេតប្រជាសាស្ត្រនិងសុខភាព ជំរឿន អង្កេតចន្លោះជំរឿន)។ | រៀងរាល់៥ឆ្នាំ | ផ្តោតលើចំនួនមរណភាពទារកទើបកើតអំឡុងពេល ២៨ថ្ងៃបន្ទាប់ពីកើតពីផ្ទៃម្តាយ | ចំនួនមរណភាពទារកទើបកើត នៅក្នុងឆ្នាំរាយការណ៍។ | ចំនួនកុមារកើតរស់សរុបនៅក្នុងឆ្នាំរាយការណ៍។ | **MOH** |

| ចំណុចដៅ | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | វដ្តនៃទិន្នន័យ | និយមន័យ | វិធីសាស្ត្រគណនាតម្លៃសូចនាករ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | ភាគយក | ភាគបែង | |
| ហោចណាស់ដល់ត្រឹម ២៥ ក្នុង១ ០០០កំណើតរស់។ | | | | | ក្នុងចំណោម ១ ០០០ ទារកកើតរស់ក្នុងពេលជាក់លាក់។ | | | |
| | ៣.៣.៣ ចំនួនលើកនៃការពិគ្រោះជំងឺក្រៅករណីថ្មីលើកុមារអាយុក្រោម៥ឆ្នាំម្នាក់ក្នុងមួយឆ្នាំ។ | ក្រសួងសុខាភិបាល | ក្រសួងសុខាភិបាល/ប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យាសុខាភិបាលតាមគេហទំព័រ | រៀងរាល់ឆ្នាំ | ផ្តោតលើចំនួនករណីថ្មីការពិនិត្យពិគ្រោះជំងឺក្រៅរបស់កុមារអាយុក្រោម៥ឆ្នាំ ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំសរុបក្នុងពេលជាក់លាក់។ | ចំនួនករណីថ្មីការពិនិត្យពិគ្រោះជំងឺក្រៅរបស់កុមារអាយុក្រោម៥ឆ្នាំ នៅក្នុងឆ្នាំរាយការណ៍។ | ចំនួនកុមារអាយុក្រោម៥ឆ្នាំសរុបនៅក្នុងឆ្នាំរាយការណ៍។ | MoH |
| ៣.៤ ត្រឹមឆ្នាំ២០៣០ បញ្ចប់ការរីករាលដាលមេរោគអេដស៍ ជំងឺរបេង គ្រុនចាញ់ ជំងឺតំបន់ត្រូពិចដែលមិនត្រូវបានយកចិត្តទុកដាក់ ជំងឺថ្លើម ជំងឺឆ្លងតាមទឹក និងជំងឺឆ្លងផ្សេងទៀត។ | ៣.៤.១ អត្រានៃករណីឆ្លងថ្មីនៃមេរោគអេដស៍ ក្នុងចំណោមប្រជាជនដែលគ្មានផ្ទុកមេរោគអេដស៍ ១ ០០០នាក់។ | ក្រសួងសុខាភិបាល។ | - អង្កេតស្តេចត្រូម (SPECTRUM)<br>- ការប៉ាន់ប្រមាណតាមលទ្ធផល AEM-ស្តេចត្រូម រៀងរាល់ឆ្នាំ | ប្រចាំឆ្នាំ | ចំនួនប្រជាជនឆ្លងមេរោគអេដស៍ថ្មី ក្នុងចំណោមចំនួនប្រជាជនដែលគ្មានមេរោគអេដស៍ ក្នុងរយៈពេល១ឆ្នាំកន្លងទៅ។ | ចំនួនប្រជាជនឆ្លងមេរោគអេដស៍ថ្មី ក្នុងរយៈពេល១ឆ្នាំកន្លងទៅ។ | ចំនួនប្រជាជនដែលគ្មានមេរោគអេដស៍ ក្នុងរយៈពេល១ឆ្នាំកន្លងទៅ។ | MOH |
| | ៣.៤.២ អាំងស៊ីដង់ (ករណីឆ្លងថ្មី) នៃជំងឺរបេង ក្នុងប្រជាជន ១០០ ០០០នាក់។ | ក្រសួងសុខាភិបាល | ក្រសួងសុខាភិបាល | រៀងរាល់ ២ឆ្នាំ | ជាករណីជំងឺរបេងដែលបានកើតថ្មីក្នុងចំណោមប្រជាជន១០០ ០០០នាក់។ | ចំនួនសរុបនៃករណីជំងឺរបេងថ្មី គ្រប់សណ្ឋាននៅក្នុងឆ្នាំរាយការណ៍។ | ចំនួនប្រជាជនសរុបក្នុងឆ្នាំរាយការណ៍។ | MOH |
| | ៣.៤.៣ អាំងស៊ីដង់ (ករណីឆ្លងថ្មី) នៃជំងឺគ្រុនចាញ់ ក្នុងប្រជាជន ១ ០០០នាក់ | ក្រសួងសុខាភិបាល | ក្រសួងសុខាភិបាល | ប្រចាំឆ្នាំ | ផ្តោតលើចំនួនករណីឆ្លងថ្មីនៃជំងឺគ្រុនចាញ់មានវត្តមាននៅមូលដ្ឋានសុខាភិបាល ក្នុងចំណោមប្រជាជន១ ០០០នាក់ | ចំនួននៃករណីថ្មីជំងឺគ្រុនចាញ់(ករណីសង្ស័យ និងជំងឺពិតប្រាកដ) ដែលមានវត្តមាននៅមូលដ្ឋានសុខាភិបាល នៅក្នុងឆ្នាំរាយការណ៍ | ចំនួនប្រជាជនសរុបនៅក្នុងឆ្នាំរាយការណ៍។ | MOH |
| ៣.៥ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឱ្យបានមួយភាគបីនៃមរណភាពមុនអាយុកាលរំពឹងទុក ពីជំងឺមិនឆ្លង តាមរយៈការការ | ៣.៥.១ អត្រាស្លាប់ដែលបណ្តាលមកពីជំងឺបេះដូង សរសៃឈាម មហារីក ទឹកនោមផ្អែម ឬជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃក្នុងចំណោមប្រជាជនអាយុពី៣០ ទៅ ៧០ឆ្នាំ។ | ក្រសួងសុខាភិបាល | ការប៉ាន់ស្មានរបស់អង្គការសុខភាពពិភពលោក | រៀងរាល់៥ឆ្នាំ | មរណភាពនៃក្រុមអាយុពី ៣០ ដល់ ៧០ឆ្នាំ ដែលបណ្តាលមកពីជំងឺបេះដូង សរសៃឈាម មហារីកទឹកនោមផ្អែម ឬជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ ក្នុង | ចំនួនមរណភាពនៃក្រុមអាយុពី ៣០ ដល់ ៧០ឆ្នាំ ដែល បណ្តាលមកពីជំងឺបេះដូង សរសៃឈាម មហារីក ទឹកនោមផ្អែម ឬជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ នៅក្នុងឆ្នាំ។ | ចំនួនអ្នកជំងឺដែលទទួលរងគ្រោះដោយជំងឺ បេះដូង សរសៃឈាម មហារីក ទឹកនោមផ្អែម ឬជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ នៅក្នុងឆ្នាំ។ | MOH |

| ចំណុចដៅ | សូចនាករ | ស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | វដ្តនៃទិន្នន័យ | និយមន័យ | វិធីសាស្ត្រគណនាតម្លៃសូចនាករ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | ភាគយក | ភាគបែង | |
| ពារនិងការព្យាបាល និងលើកកម្ពស់ភាពសុខភាពផ្លូវចិត្ត និងសុខុមាល ។ | | | | | ចំណោមអ្នកជំងឺប្រភេទនេះអាយុពី ៣០ ដល់ ៧០ឆ្នាំ។ | | | |
